# ការសំភាសន៍របស់អ៊ាម ចាន់អេង

កៈ អ្នកដែលសំភាសន៍ថន រដ្ឋា ខៈ អ្នកដែលត្រូវបានគេសំភាសន៍អ៊ាម ចាន់អេង

កៈបាទថ្ងៃនេះគឺថ្ងៃទី០២ខែអឺល...ខែ០៨ឆ្នាំ២០១៨។ ហើយខ្ញុំបាទឈ្មោះថន រដ្ឋានិងសម្ភាសន៍ទៅកាន់អ៊ុំស្រីអ៊ាម ចាន់អេង។ ដែលបច្ចុប្បន្នអ៊ុំស្រីនៅភូមិចម្ការសំរោង០២ ឃុំចម្ការសំរោង អឺល...ស្រុកបាត់ដំបង ខេត្តបាត់ដំបង។ បាទហៃអញ្ចឹងញុំចង់ជំរាបសួរទៅកាន់អ៊ុំស្រីថាអ៊ុំស្រីមានឈ្មោះពេញអ្វីដែរ?

ខៈឈ្មោះពេញអ្វីទៅ?

កៈឈ្មោះពេញគឺជាឈ្មោះនាមត្រកូល។

ខៈអឺល...ឈ្មោះពេញនាមត្រកូលឈ្មោះអ៊ាម ចាន់អេង។

កៈបាទ! ហៃអ៊ុំស្រីមានឈ្មោះហៅក្រៅទេ?

ខៈអត់មាន មានឈ្មោះតែមួយគត់ហ្នឹង។

កៈបាទ!។

ខៈឈ្មោះអ៊ាមចាន់អេង។

កៈអញ្ចឹងកាលពីក្មេងមានឈ្មោះទេ?

ខៈមានតែឈ្មោះមួយហ្នឹង។

កៈបាទ! ញុំចង់បន្តនិងមួយទៀតទៅកាន់អាយុរបស់អ៊ុំស្រីអាយុប៉ុន្មានហើយឆ្នាំហ្នឹង?

ខៈខ្ញុំឆ្នាំហ្នឹងអាយុ៦៥ឆ្នាំ។

កៈឆ្នាំខ្មែរឆ្នាំអី?

ខៈឆ្នាំខ្មែរឆ្នាំមមី។

កៈទីកន្លែងកំណើតរបស់អ៊ុំស្រីនៅណាដែរ?

ខៈទីកំណើត...កើតនៅបាត់ដំបងហ្នឹង។

កៈភូមិអី ឃុំអី?

ខៈភូមិចម្ការសំរោង០២ ឃុំចម្ការសំរោង ខេត្តបាត់ដំបង។

កៈអញ្ចឹងអ៊ុំស្រីមានបងប្អូនប៉ុន្មាននាក់ដែរ?

ខៈបងប្អូន...ខ្ញុំមានបងប្អូន០៤នាក់។ ចាស់ប្រុស០១ ស្រី០៣។

កៈហើយអ៊ុំស្រីជាកូនទីប៉ុន្មាន?

ខៈខ្ញុំជាកូនទី០២។

កៈអ៊ុំស្រីចាំឈ្មោះពួកគេទេ? ហើយពួកគេឈ្មោះអី? ឥឡូវគេនៅឯណាអញ្ចឹងណាំ?

ខៈចាស់! ចាំឈ្មោះកូនទី០១បងខ្ញុំឈ្មោះអ៊ាម ម៉េងគ័ង។ កូនទី០២ខ្ញុំឈ្មោះអ៊ាម ចាន់អេង។ កូនទី០៣ឈ្មោះអ៊ាម ចាន់ហេង។ ហើយកូនទី០៤ឈ្មោះអ៊ាម សៃយ៉ុន។ ចាស់បងប្អូនមាន០៤នាក់ប្រុស០១ ស្រី០៣។

កៈហើយគាត់នៅឯណាអីឡូវ?

ខៈបងញុំហោស? បងញុំនៅកន្លែងរោងចក្រតម្បាញគេហៅស្អីទេ?

ខៈអូនឯងស្គាល់នៅកន្លែងរោងចក្រគេតម្បាញមានដំថ្មធំៗហ៎។

កៈនៅបាត់...?

ខៈនៅបាត់ដំបងយើង។

កៈនៅបាត់ដំបងផ្សាររោងចក្រ។

ខៈនែ៎គេធ្វើផ្ទះមួយល្វែងៗ។

កៈប្រហែលជាផ្សាររោងចក្រ។

ខៈចាស៎! ផ្សាររោងចក្រ។ ហើយខ្ញុំកូនទីពីររស់នៅចម្ការសំរោង២
ហើយនិងប្អូនខ្ញុំដែលស្លាប់ទៅឈ្មោះអ៊ាម
ចាន់ហោងហ្នឹងគាត់បាត់ទាំងសង្គមលន់ណុលរហូតដល់ឥឡូវ។
ហើយប្អូនញុំមួយទៀតឈ្មោះអ៊ាម សៃយ៉ុនហ្នឹងគាត់នៅខាងគរុសល្យ។ ចាស៎!
មិនដឹងជាក្រុមប៉ុន្មានអីប៉ុន្មានទេខ្ញុំអត់ស្គាល់ទេ ចាស៎ប៉ុណ្ណឹងឯង។

កៈអញ្ចឹងអ៊ឹល...អ៊ុំស្រីមានចាំរឿងអីការពីនៅក្មេងធ្លាប់ធ្វើកិច្ចការជាមួយគ្នាទេ?

ខៈអើយ...នៅពីក្មេងៗខ្ញុំនៅជុំបងប្អូនខ្ញុំ
ដល់រៀងទ្រើសៗទៅគេក៏មានគ្រួសារក៏បែកគ្នាអស់រលីង។ចាស៎!
នៅពីក្មេងៗធ្វើការដូចជាអើយ...នៅរៀនសូត្រនៅរៀនអីជាមួយគ្នា ដើរលេងដើរអីជាមួយ

គ្នា។

កះ ចូលចិត្តធ្វើអ្វីជុំបងប្អូនហ៎?

ខះអឹម...ចូលចិត្តហ៎ ម្តាយខ្ញុំនែ៎..រៀបនឹងស្លាប់ប្រាំប្រាំមួយអើយ..មួយឆ្នាំជាងហ្នឹង ប៉ុន្តែគាត់មេម៉ាយព្រៅទេតែគាត់ច្រើនអោយខ្ញុំចេញពីរៀនមកគាត់ដូចជាមានអំពៅសាង គូលីងឈូក ដំណាប់ពន្ទាអីហ្នឹងណា៎ ហើយក៏កូនចេញពីរៀងអញ្ជឹងមកទៅតាមគាត់ជឹកឥវ៉ាន់យកទៅលក់តាមវត្តម៉ោងប្រហែល១១ ដល់ម៉ោង១២បានមកវិញ។ ប្រវត្តិញុំអញ្ជឹងចាស៎ ចេញពីហ្នឹងបាន..ទៅរៀន។

កះអញ្ជឹងអឹល...ហើយឪពុកម្តាយរបស់អ៊ុំស្រីឈ្មោះអីដែរ?

ខះឪពុកខ្ញុំឈ្មោះអិន សុជាតិ។ ម្តាយឈ្មោះចន យិន។

កះពួកគាត់មានអាយុប៉ុន្មានហើយ?

ខះមិនដឹងប៉ុន្មានផងបើមើល៎...បងខ្ញុំវាបីឆ្នាំខ្ញុំ៦៥ គាត់៦៨។

កះ៦៨។

ខះតែម្តាយខ្ញុំដែលស្លាប់មកសព្វថ្ងៃហ្នឹង..គាត់៩៧- ៩៨។

កះគិតមកដល់សព្វថ្ងៃហ្នឹង?

ខះចាស៎!។

កះកាលគាត់អឹល..មរណ:គាត់អាយុប៉ុន្មាន?

ខៈដឹងប៉ុន្មានទេភ្លេចហើយទាល់តែមើលសំបុត្រមរណៈនៅផ្ទះបងខ្ញុំ អត់ចាំដែរ។

កៈចុះឪពុកវិញ?

ខៈឪពុកម្ដាយខ្ញុំ?

កៈបាទពួកគាត់អាយុប៉ុន្មានដែរ?

ខៈមិនដឹងអាយុប៉ុន្មានទេដឹងគាត់ស្លាប់ជំនាន់គេសំនុំទម្លាក់សម្ដេចឪ ប៉ុន្មានទេអត់ចាំដែរ។ ខ្ញុំនៅតូចដែរ អាយុ១០ឆ្នាំស្លាប់ហ្នឹង។

កៈបាទ! ចុះស្រុកកំណើតរបស់ឪពុកម្ដាយរបស់អ៊ុំស្រីនៅណាដែរ?

ខៈអើយ...ស្រុកកំណើតឪពុកខ្ញុំនៅតាកែវ។ ម្ដាយខ្ញុំនៅបាត់ដំបង។

កៈអូរ...។

ខៈមិនដឹងយ៉ាងម៉ិចបានជួបគ្នានៅគូរគាត់នៅជិតគាត់នៅឆ្ងាយពេក។

កៈចាំឆ្នាំរបស់ពួកគាត់ទេគាត់កើតឆ្នាំអី?

ខៈញុំអត់ចាំ។

កៈអត់ចាំទាំងពីរនាក់?

ខៈចាស់!

កៈហើយពួកគាត់ប្រកបមុខរបស់សម្រាប់ចិញ្ចឹមជីវិតហ្នឹងគាត់ធ្វើអី?

ខ៖អើយ...ឪពុកខ្ញុំគាត់កាត់សក់តាំងពី..អើយមកតាំងពីសង្គម។

ក៖ហើយអឺល...អ៊ុំស្រីចាំរឿងរបស់គាត់ទេអនុសោវរីយ៍ដែរមានជាមួយពួកគាត់អញ្ចឹងណា៎?

ខ៖ចាស៎!

ដែលឪពុកខ្ញុំដែលបានម្ដាយខ្ញុំនៅចងចាំហ្នឹងគាត់ចាប់បានគ្នាឡើងកាលខ្ញុំនៅតូចៗនែ៎..ប៉ុនៗហ្នឹង១០ឆ្នាំជាង។

គាត់នៅគាត់នាំម្ដាយខ្ញុំហ្នឹងទៅតាកែវគាត់ឡើងទឹកត្នោតគាត់រំងាស់តែស្ករទេ ចាស៎!

ស្ករផែនស្ករអីហ្នឹងណា៎។

ក៖បាទ!។

ខ៖ចាំបានតែប៉ុណ្ណឹងឯង។ ម្ដាយខ្ញុំក៏នែ៎...

ឪពុកខ្ញុំស្លាប់ទៅក៏នែ៎..គាត់មកនៅបាត់ដំបងវិញគាត់ចេះតែរកស៊ីដូចជាលក់ផ្លែឈើអីៗកំប៉េកក៏ប៉ុកនៅផ្សារ។

ក៖កាលពីពួកគាត់នៅក្មេងគាត់មានបាននិយាយពីរឿងអីដើរទៅណាអត់?

អឺល...គាត់អត់បាននិយាយប្រាប់អ៊ុំស្រីទេថាគាត់ដើរទៅលេងណា គាត់នៅណា?

ខ៖ដែលខ្ញុំដឹងក្ដីមកមិនដែលគាត់និយាយថាដើរលេងសប្បាយចិត្តសប្បាយអីអត់មានឃើញតែគាត់រកស៊ី។

ក៖អូរ...។

ខ៖មិនដែលនាំកូនដើរលេងឯណាទេ អត់មាន។ បើថាចូលឆ្នាំគាត់នាំកូននាំថៅស្រោចទឹកទៅវត្តទៅអីហ្នឹង។ រឿងដើរលេងគឺ...។

ក៖អរគុណ!

ខ៖ចាស៎!

ក៖អញ្ចឹងអ៊ឹល...ជីដូនជីតារបស់អ៊ុំស្រីវិញជីដូនជីតាខាងឪពុកគាត់ឈ្មោះអីដែរ?

ខ៖ជីដូនជីតាឈ្មោះអ៊ឹល....។

ក៖តាយាយរបស់អ៊ុំ។

ខ៖ឪពុកខ្ញុំនឹងហ៎?

ក៖បាទ!។

ខ៖ឈ្មោះយាយ អួន តាថុល។

ក៖តាថុលណ៎។

ខ៖ចាស៎ យាយអួនឈ្មោះប្រពន្ធ តាថុលឈ្មោះប្តី។

ក៖គាត់នៅខេត្តណា?

ខ៖នៅតាកែវ។

ក៖តាកែវទាំងពីរនាក់ណ៎។

ខ៖ចាស៎!។

ក៖ហើយចុះខាងម្តាយវិញ? ជីដូនជីតាខាងម្តាយ។

ខ៖នៅតាកែវដែរ។

ក៖នៅតាកែវ។

ខ៖ចាស៎! ញុំចាំបានប៉ុណ្ណឹងទេណ៎។

ក៖ចាំឈ្មោះគាត់អត់?

ខ៖ឈ្មោះយាយអូន តាថុល។

ក៖អូរ...។

ខ៖ចាស៎!។

ក៖អឹល...ខាងម្ដាយ ខាងម្ដាយ? ជីដូនជីតាហ្នឹងខាងឪពុក ចុះខាងម្ដាយ?

ខ៖អឹល...ខាងម្ដាយខ្ញុំវិញហេស៎?

ក៖បាទ!។

ខ៖ប៉ិនគាត់ខូចៗអស់ហើយហ្នឹង។

ក៖បាទ! គាត់ឈ្មោះអីដែរ?

ខ៖ឈ្មោះ...កុងជុន ម៉ាខាំ។

ក៖បាទ!។

ខ៖ចាស៎! ខាងញុំហ៎ខាងម្ដាយញុំ។ ប៉ុនឪពុកខ្ញុំខ្មែរទេ។ ប៉ុនតែញុំមិនខ្មែរសុទ្ធរៀងកាត់ថៅចិន ប៉ុនអត់ចេះចិនផងហ្នឹង។

ក៖ពូកែរកស៊ីហ៊ឹស...។

ខ៖អត់។ ធម្មតាៗមិនមានមិនក្រ។

ក៖អញ្ចឹងបៃអឹល...ចាំថាពួកគាត់ប្រកបមុខរបរធ្វើអីទេ?

ខ៖អើយ...កុងញុំម៉ាញុំហោស៎? គាត់ធ្វើស្រែ។

ក៖ធ្វើស្រែ។

ខ៖ធ្វើស្រែនៅហួសបន្ទាយមានជ័យទៅគេហៅអី..សុទ្ធតែវាសស្រែ។

ក៖បាទ!។

ខ៖ចិញ្ចឹមគោ ធ្វើស្រែ ដាំពោតដាំអី។

ក៖អញ្ចឹង!។

ខ៖ចាស៎!។

ក៖អរគុណ! អញ្ចឹងសូមបន្តទៅទៀតហាស់....នៅចាំគ្រាន់បើ។

ខ៖ចាំញុំនិយាយ អត់ចាំញុំអត់និយាយទេ។

ក៖គ្រួសារវិញម្ដង។

ខ៖កាលនោះខ្ញុំនៅស្លៀកកំព្រងទៅរៀនដែរហ្នឹង។ រៀននៅវត្តហ្នឹង។ ហើយមុនទៅរៀនពិបាកណាស់គ្រូអើយ..សុទ្ធតែដើរលិចទឹកត្រឹមចង្កេះ ត្រឹមកអី។ ចាស់ ទាល់តែបងប្អូនអុំទូកមកយកបាន បានឆ្លងមកដល់ផ្ទះ។

ក៖អ៊ុំស្រីនៅតាកែវនឹងអឺល...រយៈពេលប៉ុន្មានឆ្នាំដែរ?

ខ៖នៅតាកែវមិនដឹងថាប៉ុន្មានឆ្នាំទេពីព្រោះម្ដាយខ្ញុំ អើយកាលនោះខ្ញុំនៅរៀន។ ហើយគាត់ទៅតាមប្ដីគាត់នៅតាកែវហ្នឹងខ្ញុំនៅរៀន អត់ចាំដែររៀងស្រពិចស្រពិលដែរ។ គេអោយលុយតែប្រាំកាក់ទៅទិញដូចជាស្ករ ប៊ីចេង អី បាត់វ៉ៃអើយ...នៅចាំតែប៉ុណ្ណឹងណាំ។ ប៉ុន្មានឆ្នាំទេត្រលប់មកវិញកាលនោះឪពុកមិនទាន់ខូចទេ។

ក៖បាទ!។

ខ៖គាត់នៅបាត់ដំបងប៉ុន្មានឆ្នាំហើយបានគាត់ក្អកធ្លាក់ឈាមក៏ខូចទៅ។ ដល់ជំនាន់គេទម្លាក់សីហានុដឹងមួយពាន់ប៉ុន្មានឆ្នាំទេ ដឹងតែមួយពាន់ស្ទើរដែរ។

ក៖អញ្ចឹងអឺល...អ៊ុំស្រីមានសាច់ញាត់នៅក្រៅប្រទេសទេ?

ខ៖អើយ...សាច់ញាតិនៅក្រៅប្រទេសដូចជាអត់មានផង។

ក៖ចុះមានអ្នករស់នៅក្រៅប្រទេសទេបងប្អូន?

ខ៖នៅក្រៅ?

ក៖នៅប្រទេសក្រៅណាំ នៅប្រទេសអាមេរិក។

ខ៖អូរ...។

កៈចុះនៅភីលីនពីនមានទេ?

ខៈអត់មានទេ។

កៈបងប្អូនណាមួយក្រែងថាបាត់ហ៎?

ខៈអើយ...ប្អូនខ្ញុំបាត់នៅបាត់ដំបងនឹងឯងកាលនោះគេគៀងហើយដល់ពេលនេះទៅគាត់ទៅធ្វើទាហាននៅទីវាលបែកចាន។

កៈបាទ!។

ខៈហើយធ្វើបានបាញ់គ្នាជំនាន់គេទំលាក់លន់ណុល។
ហើយហើយដល់ពេលនោះគិចចៀសមិនផុតទៅធ្វើទាហានក៏បាត់ខ្លួនទៅដល់ឥឡូវតាំងជំនាន់ប៉ុលពតមិនដឹងទៅរកយ៉ាងម៉ិច។ ជំនាន់នេះមិនដឹងថាទៅរកយ៉ាងម៉ិច?

កៈបាទអញ្ចឹង សូមបន្តអឺល...អត់មានសាច់ញាត្តិក្រៅប្រទេស? គាត់..ឈ្មោះអីថាបាត់ខ្លួន?

ខៈឈ្មោះ អ៊ាម ចាន់ថេង។

កៈអ៊ាមចាន់ថេង។ ប្រាប់ពីមូលហេតុអ្វីបានជាគាត់បាត់?

ខៈ
មូលហេតុដែលគាត់បាត់នឹងគេតម្រូវឪ្យយើងទៅធ្វើទាហានមោហើយគេចមិនផុតក៏ស្ម័គ្រចិត្តបណ្តោយទៅកាលនោះអាយុប៉ុន្មានទេ? ប្រហែលជា១៥,
១៦អីនឹងនៅក្មេងដែរនឹងមិនដឹងទៅរកឯណា។

កៈ អត់ដឹងថាគាត់ទៅក្រៅទៅអីណោះ!។

ខ៖ អត់ដឹង! អត់ដឹងមិនដឹងស្រាវជ្រាវតាមណាអត់ដឹងព្រោះខ្ញុំអត់ស្គាល់គេ យូរឆ្នាំហើយដែរនឹង។

ក៖ អញ្ចឹងអគុណច្រើនអញ្ចឹងចង់ជំរាបសួរទាក់ទងរឿងអាពាហ៍ពិពាហ៍ហើយ អ៊ំប្រុសឈ្មោះអីដែរ?

ខ៖ អឺ..ប៉ាខ្ញុំនឹងហ៎ ឈ្មោះអិន សុជាតិ។

ក៖ អិន សុជាតិ ហើយស្រុកកំណើតគាត់នៅណា៎?

ខ៖ នៅតាកែវ។

ក៖ តាកែវ!។

ខ៖ ចា៎។

ក៖ អឺ..ចាំថ្ងៃខែឆ្នាំរៀបអាពាហ៍ពិពាហ៍ទេ? សំនួរចង់សួរថា អាពាហ៍ពិពាហ៍នឹងត្រូវបានរៀបចំឡើងដោយចាស់ទុំ រឺក៏ស្រលាញ់គ្នា..?

ខ៖ អាពាហ៍ពិពាហ៍ រៀបចំត្រឹមត្រូវអត់មានរត់តាមគ្នាទេ អើយៗ ម្ដាយឪពុកខាងប្រុសនឹងគេមកដណ្ដឹងត្រឹមត្រូវ ចា៎អាពាហ៍ពិពាហ៍ត្រឹមត្រូវ អត់មាននេះទេ។

ក៖ អឺ..ខាន់ស្លាមិចដែរ មានខាន់ស្លាទេ?

ខ៖ មានខាន់ស្លា។

ក៖ ប៉ុន្មានដែរ?

ខ៖ អង្កាលនុង ថ្លៃដែរនឹង មិនដឹងប៉ុន្មានទេ ហើយដល់ហ្គា..រៀបចំការបានត្រឹមត្រូវអញ្ចឹងបានកន្លះខែ ក៏នាំគ្នាទៅធ្វើអីតាស៊ីវិលអញ្ចឹងទៅ។

ក៖បាទ!។

ខ៖ ប៉ុន្តែដល់ពេលសម័យប៉ុលពត ក៏ចេះតែទុកៗទៅមិនដឹងទៅណាអស់ ប្ដីខ្ញុំគេសំលាប់ចោល ក៏បាត់រប៉ាតរប៉ាយអស់ទៅណាំ..។

ក៖ បាទ! អ៊ំស្រីដឹងពីមូលហេតុថាអី....ហេតុអីបានជាអី...មូលហេតុដែលបានជួបគ្នាដំបូងនឹងណា ជួបគ្នាដោយរបៀបណា..ស្គាល់គ្នា?

ខ៖ ខ្ញុំៗខ្ញុំហើយនឹងតាខ្ញុំនឹង ហ្អរ។

ក៖ បាទ។

ខ៖ ជួបគ្នាដោយដំបូង មិនមែនជួបដោយស្រលាញ់គ្នាដូចគេទេ ម្ដាយឪពុកគេមកដណ្ដឹងខ្ញុំ ប៉ុន្តែខ្ញុំប្រកែកថាខ្ញុំមិនយក ឪ្យបងខ្ញុំទៅ បងខ្ញុំថាមិនយកទេ អញ្ចឹងវាធ្លាក់មកនៅលើខ្ញុំ ហើយខ្ញុំមិនស្រលាញ់គាត់ទេ ហើយចាស់ៗគាត់គិតតែពីសុំឪ្យទៅ ហើយខ្ញុំនឹកឃើញដែរ ខ្ញុំថាហ្អឺ..មិនដឹងធ្វើមិចទេបើគេចូលមកផ្លូវល្អអញ្ចឹងហើយ...រហូតទល់តលូវទោះនៅក៏មិនបានសុខ វាណាយនឹងគ្នាវាអត់ស្រលាញ់គ្នានោះ ចាំ។

ក៖ អញ្ចឹងអីៗប្ដីរបស់អ៊ំស្រីអី ជាលក្ខណ:អីៗ  ម្ដាយឪពុកគាត់រៀបចំឪ្យ..។

ខ៖ ចាំ.. កាលនោះមាស ១ជី ៣រយ ខ្ញុំចាំដែរ ១ជី ៣រយខ្មែរនឹង ហ្អាំ លុយថ្លៃណាស់កាលនុងហ្អរ..

កៈ អញ្ចឹងស្គាល់គ្នាដំបូងតាមរយៈចាស់ៗ?

ខៈចាស់ៗ។

កៈ បាទ អញ្ចឹងខ្ញុំចង់ជំរាបសួរទាក់ទងភាសាវិញម្តង ក្រៅពីភាសាខ្មែរ តើអ៊ំស្រីមានចេះភាសាអីផ្សេងទៀតទេ?

ខៈ ខ្ញុំចេះតែភាសាខ្មែរ អង់គ្លេសខ្ញុំមិនសូវចេះទេ ចេះស្ទើ មិនចេះ ថាមិនចេះតែម្តងទៅ ចេះតែភាសាខ្មែរ។

កៈ ចុះភាសាចិនថៃ?

ខៈអត់ចេះ យួនក៏អត់ចេះ។

កៈ អញ្ចឹងជាបន្ទាប់មកទៀតអឺ ទៅទៀត ខ្ញុំសូមជំរាបសួរទាក់ទងនឹងខ្សែជីវិតរបស់អឺ អ៊ំស្រីវិញម្តង អញ្ចឹងការសិក្សាវិញកាលពីដើមរៀននៅសាលាណាដែរ?

ខៈ ខ្ញុំចេញពីស្រុកមក រស់នៅជាមួយម្តាយខ្ញុំស្រុកខ្ញុំនៅខាងបន្ទាយមានជ័យ ចំដូងស្ងួតជិតដល់ឃុំសំបួរ
ម្តាយទៅយកពីនឹងមករៀននៅបាតដំបងមកនៅរៀននៅជាមួយម្តាយបង្កើតមួយមិញគាត់ផ្ញើរ ខ្ញុំនៅជាមួយម្តាយគាត់បង្កើតហើយនឹងមាខ្ញុំនឹងណាស់
យកមកនៅបាតដំបងខ្ញុំរៀនត្រឹមបានថ្នាក់ទី៧ទេពីសង្គមចាស់។

កៈ កាលនៅរៀនអ៊ំស្រីមានមិត្តភក្តស្និតស្នាលទេ?

ខ៖ មានដែរ-ឥលូវភ្លេចអស់បាតហើយ

មិនដឹងគេនៅណាគេមានប្តីមានគ្រួសារអស់មិនដឹងនៅណាណីផង។

ក៖ ចាំឈ្មោះរបស់ពួកគាត់ទេ?

ខ៖ ចាំមិនដឹងគេនៅណាហើយ គ្រូនៅច្រើនដែរ

មិនៗថាអ្នកណារៀនអត់មានពួកម៉ាកមានប៉ុន្តែឥលូវខ្ញុំចំនាស់ៗនេះខ្ញុំភ្លេចអស់ហើយ។

ក៖ ឈ្មោះអីគេ? ចាំឈ្មោះមួយពីរទេ។

ខ៖ សុម៉ាលី ហើយក៏ស៊ីណា ហើយនាងហឿន ច្រើនដែរមួយថ្នាក់៥០នាក់ដែរ ខ្ញុំចាំអត់អស់។

ក៖បាទ!

ខ៖ណាមានគ្រួសារ ណាទៅស្រុកក្រៅ ណាជួបគ្នាសើចដាក់គ្នា។

ក៖សំរាប់អ៊ំស្រីវិញអ៊ី..រាល់ថ្ងៃប្រកបមុខរបរតាំងពីមុនមកប្រកបមុខរបរធ្វើ ស្រែ

ចំការឬក៏ជាអ្នកលក់ដូរ?

ខ៖ ចា ពីមុនមកខ្ញុំអ៊ីយ លក់ដូរកំប៉េចកំប៉ុកអញ្ចឹងឯងនៅផ្សារ

ដល់អាខ្ញុំរាងដូចមិនសុវស្រួលខ្លួនអត់ងងុយអត់អី ខ្ញុំមករកស៊ីកំប៉េចកំប៉ុកតាមផ្ទះវិញ

មុនខ្ញុំក្រោកម៉ោង១ម៉ោងអីទៅលក់ក្រូចលក់អីអញ្ចឹងដល់វារៀបភ្លឺ

ខ្ញុំត្រលប់មកវិញហើយទ្រាំនឹងអត់ងងុយមិនបានចេះតែឈឺពេក

ខ្ញុំរករបរណាដែលខ្ញុំដូចថាដេកឆ្អែតអញ្ចឹង ដេកមិនឆ្អែតអញ្ចឹង

វាដូចជាវិលសឺៗអញ្ចឹងបើលុយអញ្ចេះក៏ចាយអត់គ្រប់ដែរប៉ុន្តែមិនដឹងធ្វើមិច

ចាយតាមដំណើររឿងលុយដែលយើងរកបានប៉ុន្នាយើងគិតប៉ុន្នឹងទៅ។

កៈ បាទ អគុណច្រើន

អញ្ចឹងអ៊ីកាលពីនៅក្មេងរហូតមកដល់ពេលនេះតើការរស់នៅដូចជាជីវិតរបស់អ៊ំស្រីមានការផ្លាស់ប្តូរអ្វីខ្លះទេ?

ខៈ ផ្លាស់ប្តូរអីលោកគ្រូ ផ្លាស់ប្តូរ ឈឺស្កាត់។

កៈ ពិបាកជាងមុនឬ ក៏ស្រួលជាងមុន ឬក៏ ឈឺស្កាត់?

ខៈ ហ្អុំ! ជីវភាពនឹង ហ្អ។

កៈបាទ។

ខៈ ជីវភាព..ពីមុនឥលូវដែលខ្ញុំ..ពីក្មេងមកមិនសូវមានឈឺទេ

ដល់ចំណាស់ប៉ុន្នេះវារាងឈឺៗមិនឈប់ បើថាឈឺនេះឈឺនោះ ជួនកាលវារោយក

ជួនកាលវាវិលមុខ ជួនកាលទៅអត់ហូបបាយដូចវាឆ្អែតឯងជួនកាលវាឆ្អល់ក្រពះអញ្ចឹង

ទៅថ្ងៃណាក៏វាជាដើរភឹតអញ្ចឹងទៅ ចាំវាប្រែប្រួលតាមនឹងដែរ។

កៈ អគុណច្រើន!

ខៈ ចាំ។

កៈ ទាក់ទងនឹងម្ហូបវិញអ៊ំស្រីចូលចិត្តពិសារម្ហូបអ្វីដែរតាំងពីក្មេងមកដល់ឥលូវនឹងណាំ?

ខៈ ខ្ញុំហ្អែស អត់មានរើសទេ ស្អីក៏ខ្ញុំហូបដែរ

ឆាស្ងោចៀនអាំងអីក៏ខ្ញុំហូប..តាមតែលិទ្ធភាពរកបាន។

កៈ ចុះម្ហូបដែលចូលចិត្តជាងគេ..ហ្អាំ អីគេ?

ខ៖ សំល ម្ជូរយួន ឆាគ្រឿង ឆាអី ស្ងោជ្រក់ស្ងោអី លោកគ្រូ ប៉ុន្នឹងឯង។

ក៖ បាទ អគុណ ហើយចុះទាក់ទងនឹងចំរៀងវិញ ចូលចិត្តចំរៀងតារារូបណាដែរ?

ខ៖ រឿងចំរៀងអត់សូវចេះច្រៀង..អត់ដែលច្រៀងអញ្ចឹងម៉ង ហើយនឹងរាំ

ហើយបើតា..គាត់ចេះម៉ាចប់រាំច្រៀងក្បាច់..ស្អីក៏គាត់ចេះដែរច្រៀង អន្លុងអន្លូចមែនទែន

តាខ្ញុំវាអត់ចេះ ខុសគ្នាម៉្យាងម្នាក់។

ក៖ អញ្ចឹងអ៊ី អ៊ំស្រីអ៊ី ក្នុងក្រុមគ្រួសាររបស់អ៊ំស្រី..មានអ្នកចេះលេងឧបករណ៍តន្រ្តីទេ?

ខ៖ អត់មានទេអូន មានតែអ្នកធ្វើការ។

ក៖ នឹង..អញ្ចឹងខ្ញុំសូមបន្តបន្តិចទៀត..ទាក់ទងនឹងអ៊ី..ហ្អឺ..ទាក់ទងនឹងផ្ទះវិញ

ហើយផ្ទះពីដើមនឹងផ្ទះឥលូវមានលក្ខណៈខុសគ្នាទេ?

ខ៖ អើយ..ផ្ទះពីដើមនឹងផ្ទះឥលូវមានលក្ខណៈខុសគ្នា ផ្ទះពីដើមមកខ្ញុំរកតែផ្ទះនៅមិនបាន

ហើយគ្មានទាំងកន្ទេលដេកគ្មានទាំងមុងដេក គ្មានទាំងទីលំនៅពិតប្រាកដ

ទាលតែខ្ញុំចេញពីស្រុកមក បានខ្ញុំមកទើរនៅត្រង់នេះឯង

នៅចំកាសារ៉ងទីនៅបានជាជិសាមសិបឆ្នាំចាំ នៅនឹងនេះឯង។

ក៖ បាទ។

ខ៖ ចាំ ។

ក៖ អញ្ចឹង..ហ្អឺ..ទាក់ទងនឹងឧបសគ្គវិញ បានន័យថាទុក្ខលំបាកអញ្ចឹងណាស់ បាទ។

ខ៖ ឧបសគ្គក្នុងជិវិត ទុក្ខលំបាក ពិបាកចិត្តគ្រប់បែបសព្វនឹងឯង

ពិបាកចិត្តថាយើងធ្វើជាម្ដាយគេរកស៊ីចិញ្ចឹមកូនមិនបានគ្រប់គ្រាន់

ថ្ងៃណាតូចចិត្តខ្លួនឯងក្រផង គ្មានមុខរបរអីត្រឹមត្រូវសំរាប់ឲ្យកូនសប្បាយចិត្ត

ក្រពេកជីវភាពគឺថារកបានបួនប្រាំពាន់ត្រូវចំណាយអស់មួយម៉ឺនពីរម៉ឺនមួយថ្ងៃអញ្ចឹងហ្អាស

អានឹងអត់សប្បាយចិត្តទេ។

ក៖ អញ្ចឹងទាក់ទិននឹងបទពិសោធល្អៗវិញកាលពីនៅក្មេងរហូតមកដល់ឥលូវនឹង

មានធ្លាប់បានធ្វើរឿងអីល្អៗទេ ដែលអាចចាំបានអញ្ចឹងណាស់។

ខ៖ ធ្វើរឿងអីល្អ ដូចថាយើងចេះស្រលាញ់ញាតិជិតខាង មិនឈ្លោះនឹងគេ

ម្ដាយឪពុកព្រមានណែនាំអីយើងស្ដាប់គាត់ទាំងអស់ អត់មានភ្លឹតភ្លីនទៅ មានមិត្តភក្ដប៉ែឡៃ

ប៉ោឡោអត់មាន ខ្ញុំអត់ចេះដើរអញ្ចឹងម៉ងពីក្មេងអត់ចេះដើរ អត់ចេះអីផង ចាំ អត់ដឹងដែរ។

ក៖ ល្អមែនទែន។

ខ៖ ចាំ កូនឥលូវអត់ដូចខ្ញុំទេ លោកគ្រូអើយ ខុសគ្នា។

ក៖ជាបន្តខ្ញុំចង់ជំរាបថា..អឺ..ខាងក្រុមការងាររបស់ខ្ញុំគឺជាក្រុមការងារមួយដែល

ដើម្បីរក្សាប្រវត្តិបងប្អូនពុកម៉ែយើងនោក្នុងប្រទេសកម្ពុជាយើងនឹងណា

ដើម្បីរក្សាឯកសារទាំងអស់នេះ

ទាក់ទងនឹងកំណត់ត្រាសំលេងនេះទុកឲ្យកូនចៅជំនាន់ក្រោយ

ហើយដើម្បីពួកខ្ញុំអាចរៀនសូត្រអំពីជីវប្រវត្ត ក៏ដូចជាទុក្ខលំបាក

ហើយនឹងការអ្វីដែលល្អប្រសើរ បទពិសោទផ្សេងៗអញ្ចឹងណា អញ្ចឹង អគុណច្រើនសំរាប់

ការផ្ដល់អនុសាសន៍ក៏ដូជាការផ្ដល់ជាបទពិសោទដល់ពួកខ្ញុំអញ្ចឹងណា

ហើយពួកខ្ញុំនឹងរៀបចំជូនជាCDជូនទៅកាន់អ៊ំស្រីនៅសំលេងហើយនឹងក្នុងនោះមានរូបថតអ

ញ្ជឹងណា ហើយជាចុងក្រោយអ៊ំស្រីមានការផ្តាំផ្ញើរ

ឬមានមតិយោបល់អីសំរាបឲ្យកូនចៅជំនាន់ក្រោយគាត់អាចស្តាប់លឺទេ?

ខ៖ មិនដឹងគេស្គាល់ខ្ញុំអត់ទេ ទាល់ឃើញរូបថត..អើយខ្ញុំចង់ផ្តាំផ្ញើរដល់ក្មេងជំនាន់ក្រោយ

ដែលគេរស់នៅជំនាន់ក្រោយនេះគេ..អើយគេដូចថាមាន របបគេថ្មីអញ្ចឹងណា

គេកើតមកមានសំណាងជាងខ្ញុំគេសប្បាយជាងខ្ញុំ

តែជំនាន់ខ្ញុំកើតទុក្ខច្រើនហើយណាប្រឹងរៀនផងប្រឹងរកស៊ីផងម្តាយក៏ម៉េម៉ាយព្រៅ

ដូចអត់សប្បាយចិត្តមកហើយខំប្រឹងដោយខ្លួនឯងម្តាយក៏ប្រឹងកូនក៏ប្រឹងដើម្បីតែកូនកុំឲ្យតែកូ

នល្ងង់ខ្លៅ កាលក្មេងៗជំនាន់នេះសប្បាយច្រើនបើកភ្នែកមកទារតែលុយម្តាយទៅរៀនប្រុយ

បើម៉ែឲ្យតិចៗមិនទៅផង តែខ្ញុំអត់ម៉ែឲ្យប៉ុន្នាទៅប៉ុន្នឹងមកវិញជួយធ្វើការម៉ែឪលក់ដូរទៀត។

ក៖ ចុះសំណូមពរចង់ឲ្យ ក្មេងជំនាន់ក្រោយមិចដែរ?

ខ៖ ឲ្យល្អជាងខ្ញុំ កុំឲ្យដូចខ្ញុំ ខ្ញុំវេទនាចង់ងាប់។

ក៖ បាទ ឲ្យគាត់ខំប្រែងសិក្សារៀនសូត្រឲ្យចេះ។

ខ៖ចាំ ឲ្យគាត់ខំប្រែងសិក្សារៀនសូត្រឲ្យបានមានការងារធ្វើមិនដូចខ្ញុំទេ

ដូចខ្ញុំវានៅក្រណាស់។

ក៖ បាទ អញ្ចឹងអគុណច្រើនសំរាប់ប៉ុន្នឹង បាទជំរាបលា។

ខ៖ ពិរោះមិនពិរោះលោកគ្រូកុំថាខ្ញុំណា។

ក៖ បាទអត់អីទេ។